រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ :១៤៣៤ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ
- បានឃើញសេចក្តីសម្រេចលេខ ១២ ស.ស.រ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- បានឃើញបទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១ .–**

អនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់ខ្លួន ដើម្បីជាគុណប្រយោជន៍ដល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២ .–**

សេវារដ្ឋបាល ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំជាកម្រងសេវារដ្ឋបាល ដែលមានរាយលម្អិតអំពីតម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវារដ្ឋបាលនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

តម្លៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ រួមមានពីរប្រភេទ: ប្រភេទទី១ ត្រូវបានកំណត់ជាតម្លៃអតិបរមា និងប្រភេទទី២ ត្រូវបានកំណត់ជាតម្លៃជាក់លាក់។

**ប្រការ៣ .–**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវដាក់ចេញនូវដីកាដើម្បីកំណត់តម្លៃសេវារដ្ឋបាលជាក់ស្តែង សម្រាប់ប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ប៉ុន្តែមិនត្រូវលើសពីតម្លៃអតិបរមា ដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះឡើយ។ ដោយឡែកចំពោះតម្លៃជាក់លាក់ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ពុំមានសិទ្ធិកែសម្រួលតម្លៃសេវារដ្ឋបាលទាំងនោះឡើយ។

នីតិវិធី និងបែបបទនៃការរៀបចំដាក់ចេញដីកានេះ ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ និងសេចក្តីសម្រេចលេខ ០៧០ សសរ/គឃស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់។

**ប្រការ៤ .–**

ក្នុងការកំណត់តម្លៃសេវារដ្ឋបាលនេះ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវពិចារណាអំពីការកំណត់តម្លៃអនុគ្រោះ ចំពោះប្រជាពលរដ្ឋដែលមានប័ណ្ណក្រីក្រនៅមានសុពលភាព ដែលបញ្ជាក់ទទួលស្គាល់ដោយមេឃុំ ចៅសង្កាត់។

**ប្រការ៥ .–**

ពាក្យស្នើសុំសេវារដ្ឋបាល នឹងត្រូវផ្តល់ជូនដោយមិនយកកម្រៃ។ រាល់សំណុំបែបបទ និងឯកសារនៃការផ្តល់សេវារដ្ឋបាលមិនតម្រូវឱ្យបិទតែមប្រិ៍សារពើពន្ធឡើយ។

**ប្រការ៦ .–**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំប្រមូល និងចងក្រងប្រភេទ និងតម្លៃសេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន ព្រមទាំងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួចផ្ញើជូនក្រសួងមហាផ្ទៃ ០១ច្បាប់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ច្បាប់ អង្គភាពប្រឆាំងអំពើពុករលួយ ០១ច្បាប់ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ០១ច្បាប់ សម្រាប់តាមដានការអនុវត្ត។

**ប្រការ៧ .–**

នីតិវិធីនៃការត្រួតពិនិត្យនីត្យានុកូលភាពលើដីការបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវអនុវត្តតាមជំពូកទី៧ មាត្រា៣៦ មាត្រា៣៧ និងមាត្រា៣៨ នៃអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ និងសេចក្តីសម្រេចលេខ ០៧០ សសរ/គឃស ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់។

**ប្រការ៨ .–**

រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ត្រូវបិទផ្សាយជាសាធារណៈលើក្តារព័ត៌មាននៅកន្លែងផ្តល់សេវារដ្ឋបាលនៃថ្នាក់រដ្ឋបាលនីមួយៗ និងធ្វើការផ្សព្វផ្សាយព័ត៌មានតាមមធ្យោបាយផ្សេងៗទៀត នូវស្តង់ដារសេវារដ្ឋបាល ក្នុងនោះរួមមាន ÷ តារាងកម្រងសេវារដ្ឋបាល ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវារដ្ឋបាល និងការបង់កម្រៃសេវារដ្ឋបាល។

**ប្រការ៩ .–**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំបង្កើតឱ្យមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមលិខិតបទដ្ឋានដែលនៅជាធរមាន។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យប្រជាពលរដ្ឋ ត្រូវបន្តអនុវត្តការទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ាដែលពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ១០ .–**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបានពីកម្រៃសេវារដ្ឋបាលរបស់ខ្លួន។

រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ចំណុះរាជធានីភ្នំពេញ ត្រូវបង់ប្រាក់ចំណូលចូលថវិការាជធានីភ្នំពេញ។

រដ្ឋបាលសង្កាត់ចំណុះក្រុង ត្រូវបង់ប្រាក់ចំណូលចូលថវិកាក្រុង។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក ត្រូវបង់ប្រាក់ចំណូលចូលថវិការបស់រដ្ឋបាលសាមី និងផ្ញើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូល នៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ១១ .–**

រាល់ការទទួលប្រាក់ចំណូលពីកម្រៃសេវារដ្ឋបាលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២ .–**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវរៀបចំឱ្យមានយន្តការនៃការផ្តល់សេវារដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមលក្ខណៈជាច្រកចេញចូលតែមួយ ដើម្បីទទួលបម្រើសេវាជូនប្រជាពលរដ្ឋ និងធុរជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

នៅក្នុងអំឡុងពេលដែលពុំទាន់បង្កើតបាននូវយន្តការច្រកចេញចូលតែមួយ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវកំណត់ទីតាំងជាក់លាក់ណាមួយ និងត្រូវមានមន្ត្រីប្រចាំការនៅទីកន្លែងផ្តល់សេវា ដើម្បីទទួលបម្រើសេវាជូនប្រជាពលរដ្ឋ និងធុរជន តាមគោលការណ៍ដែលបានកំណត់។

**ប្រការ១៣ .–**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានយន្តការផ្តល់សេវារដ្ឋបាល តាមការិយាល័យច្រកចេញចូលតែមួយ ត្រូវបន្តអនុវត្តតាមយន្តការនេះ។

ចំណូលដែលប្រមូលបានពីការផ្តល់សេវារដ្ឋបាលតាមការិយាល័យច្រកចេញចូលតែមួយ ត្រូវបានអនុញ្ញាតឱ្យកត់ត្រាជាចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី។

**ប្រការ១៤ .–**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ក្រៅពីរាជធានី និងក្រុង ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តសាមី ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវបូកសរុប និងផ្ញើរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៃរាជធានី ខេត្តសាមី ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី២០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី៣១ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ១៥.-**

តម្លៃអតិបរមានៃសេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានដោយផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការកែប្រែតម្លៃអតិបរមានេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១៦ .-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មានសិទ្ធិចេញដីកាកែប្រែតម្លៃសេវារដ្ឋបាលជាក់ស្តែងសម្រាប់ប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អនុលោមតាមការកែប្រែតម្លៃអតិបរមានៃសេវារដ្ឋបាល ដោយរដ្ឋបាលថ្នាក់ជាតិ ឬ ផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ឬ ផ្អែកតាមកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

**ប្រការ១៧ .-**

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវរួសរាន់ដាក់ចេញនូវដីកាស្តីពីការកំណត់តម្លៃសេវារដ្ឋបាលជាក់ស្តែង សម្រាប់ប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧។

ក្នុងករណីដែលក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ មានការយឺតយ៉ាវពុំបានដាក់ចេញនូវដីកាស្តីពីការកំណត់តម្លៃសេវារដ្ឋបាលជាក់ស្តែង សម្រាប់ប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានទាន់ពេលវេលាទេនោះ ត្រូវអនុវត្តជាបណ្តោះអាសន្នទៅតាមតម្លៃសេវារដ្ឋបាលដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ១៨ .-**

ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងដូចខាងក្រោម ÷

- ប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ ៦៧៤៤ ប្រក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ស្តីពីការកែប្រែតម្លៃសេវារដ្ឋបាលនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២០ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គស្នងការ អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

### តារាងឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ...១៤៣៤ ប្រក...ចុះថ្ងៃទី...២៩... ខែ...ធ្នូ... ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក. រដ្ឋបាលរាជធានី ខេត្ត**

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| **១. ការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង)** | | | | | | |
| ១ | សេចក្តីអនុញ្ញាតឱ្យប្រកបអាជីវកម្ម អាហារ៉ាណ នីហារ៉ាណ សណ្ឋាគារវិនិយោគទុនបរទេស | ២០ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ២ | លក្ខន្តិកៈក្រុមហ៊ុនអាជីវកម្មនានា វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន លិខិតក្រសួងពាណិជ្ជកម្ម កិច្ចសន្យា | ១០ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៣ | ប្លង់សាងសង់ | ២ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៤ | វិញ្ញាបនបត្រសម្គាល់ម្ចាស់កម្មសិទ្ធិអចលនវត្ថុ | ២ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៥ | សញ្ញាបត្រក្រោយឧត្តមសិក្សា (ក្នុងប្រទេស) | ២ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៦ | សញ្ញាបត្រពុទ្ធិកសិក្សា | ២ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៧ | លិខិតអនុញ្ញាតចុះបញ្ជីសមាគម អង្គការ ព្រះវិហារសាសនា និងសហគមន៍ | ១ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៨ | លិខិត ឬឯកសារផ្សេងៗទៀត (ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) | ១ ០០០ | | ៥ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| **២. ការងាររដ្ឋបាល** | | | | | | |
| ១ | ការអនុញ្ញាតឱ្យជីកឆ្លងផ្លូវ ឬតាមបណ្តោយផ្លូវក្នុងរាជធានីភ្នំពេញ (ចំពោះការជួសជុលផ្លូវឡើងវិញឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចដើម គឺជាកាតព្វកិច្ចរបស់អ្នកស្នើសុំ) | ៥០០ ០០០ | | ១៥ ថ្ងៃ | កំណត់ដោយរដ្ឋបាលរាជធានី ខេត្ត | ១ ច្បាប់ |
| ២ | ការអនុញ្ញាតឱ្យជីកឆ្លងផ្លូវ ឬតាមបណ្តោយផ្លូវក្នុងខេត្ត (ចំពោះការជួសជុលផ្លូវឡើងវិញឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចដើម គឺជាកាតព្វកិច្ចរបស់អ្នកស្នើសុំ) | ២០០ ០០០ | | ១៥ ថ្ងៃ | | ១ ច្បាប់ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| ៣ | លិខិត/ប័ណ្ណឆ្លងព្រំដែន (laissez-passer) | | ២០ ០០០ | ៥ ថ្ងៃ | ១ លើក | ១ ច្បាប់ |
| ៤ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជន | | | | | |
| ៤.១ | ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | | | | | |
| | - ដីដែលមានទំហំចាប់ពី ១ ០០០ម៉ែត្រការ៉េ ដល់ក្រោម ៥ ០០០ម៉ែត្រការ៉េ | ៦០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ៥ ០០០ម៉ែត្រការ៉េ ដល់ក្រោម ១០ ០០០ម៉ែត្រការ៉េ | ៨០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ១០ ០០០ម៉ែត្រការ៉េឡើង | ១ ៦០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| ៤.២ | ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | | | | | |
| | - ដីដែលមានទំហំចាប់ពី ១ ០០០ម៉ែត្រការ៉េ ដល់ក្រោម ៥ ០០០ម៉ែត្រការ៉េ | ៣០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ៥ ០០០ម៉ែត្រការ៉េ ដល់ក្រោម ១០ ០០០ម៉ែត្រការ៉េ | ៤០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ១០ ០០០ម៉ែត្រការ៉េឡើង | ៨០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| ៥ | លិខិតអនុញ្ញាតទីតាំងប៉ាណូអចល័ត (គិតក្នុង ១ម៉ែត្រការ៉េ) | ១០០ ០០០ | | ៤៥ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៦ | ការចុះបញ្ជីវិនិយោគជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (ទុនវិនិយោគក្រោម ២លានដុល្លារអាមេរិក) | | ៧ ០០០ ០០០ | ២៨ ថ្ងៃ | ១ លើក | ១ ច្បាប់ |

## ខ. រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យច្រកចេញចូលតែមួយ

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| **១. ការងារនីត្យានុកូលកម្ម(ការបញ្ជាក់លើឯកសារថតចម្លង)** | | | | | | |
| ១ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាកំរិត១ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាកំរិត២ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៤ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាបឋមភូមិ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៥ | វិញ្ញាបនបត្របណ្តោះអាសន្ន មធ្យមសិក្សាទុតិយភូមិ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៦ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា ថ្នាក់ទី១២ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៧ | វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៨ | វិញ្ញាបនបត្រប្រកបអាជីវកម្ម | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៩ | ប័ណ្ណប៉ាតង់ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១០ | វិញ្ញាបនបត្រ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១១ | លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ១២ | លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកំរិត១ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៣ | សញ្ញាបត្រមធ្យមសិក្សាកំរិត ២ (បំពេញវិជ្ជា) | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៤ | សញ្ញាបត្រមធ្យមសិក្សា ទុតិយភូមិ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៥ | សញ្ញាបត្រមធ្យមសិក្សា គរុកោសល្យ | ១ 000 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| ១៦ | សញ្ញាបត្រមធ្យមសិក្សា | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៧ | សញ្ញាបត្រគ្រូបង្រៀនកំរិតឧត្តម | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១៨ | ព្រឹត្តិបត្រលទ្ធផលប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ១៩ | បរិញ្ញាបត្រ | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២០ | បរិញ្ញាបត្ររង | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២១ | លិខិតបញ្ជាក់ការសិក្សា | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២២ | អត្តសញ្ញាណប័ណ្ណ | ០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២៣ | សៀវភៅស្នាក់នៅ | ០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ២៤ | ប័ណ្ណសំគាល់យានយន្ត | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២៥ | ប័ណ្ណបើកបររថយន្ត | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ២៦ | ព្រឹត្តិបត្រពិន្ទុ | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ២៧ | ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកំរិត២ ចំណេះដឹងទូទៅ | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២៨ | វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាបត្រ | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២៩ | វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាបត្ររង | ១ ០០០ | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| **២. ការងាររដ្ឋបាល** | | | | | | |
| ១ | **ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជនមិនលើសពី១ ០០០ម៉ែត្រការ៉េ** | | | | | |
| ១.១ | **ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងនៃខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប** | | | | | |
| | - ដីដែលមានទំហំក្រោម ១០០ម៉ែត្រការ៉េ | ១០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ១០០ម៉ែត្រការ៉េ ដល់ក្រោម ៥០០ម៉ែត្រការ៉េ | ២០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ៥០០ម៉ែត្រការ៉េ ដល់ក្រោម ១ ០០០ម៉ែត្រការ៉េ | ៤០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| ១.២ | **ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប** | | | | | |
| | - ដីដែលមានទំហំក្រោម ១០០ម៉ែត្រការ៉េ | ៥០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ១០០ម៉ែត្រការ៉េ ដល់ក្រោម ៥០០ម៉ែត្រការ៉េ | ១០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| | - ដីដែលមានទំហំចាប់ពី ៥០០ម៉ែត្រការ៉េ ដល់ក្រោម ១ ០០០ម៉ែត្រការ៉េ | ២០០ ០០០ | | ១០ ថ្ងៃ | | ១ ច្បាប់ |
| **៣. ការងារអត្រានុកូលដ្ឋាន** | | | | | | |
| ១ | សេចក្ដីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | 0 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២ | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ | 0 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣ | សេចក្ដីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព | 0 | | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| ៤. វិស័យវប្បធម៌ និងវិចិត្រសិល្បៈ | | | | | | |
| ៤.១. កម្មវិធីសម្តែងផ្សេងៗ (ក្រៅផ្លូវការ) | | | | | | |
| ១ | ការប្រគំតន្ត្រីនៅទីសាធារណៈ | | ៤០០ ០០០ | ៧ ថ្ងៃ | ១ លើក | ១ច្បាប់ |
| ២ | ការសម្តែងទស្សនីយភាពល្ខោន លក់សំបុត្រ | | ០ | ៧ ថ្ងៃ | ១ លើក | ១ច្បាប់ |
| ៣ | អាជីវកម្មរាំកំសាន្ត លក់សំបុត្រ | | ១៥ ០០០ | ៧ ថ្ងៃ | ១ ថ្ងៃ | ១ច្បាប់ |
| ៤.២. ការបញ្ចាំងភាពយន្ត វីដេអូ | | | | | | |
| ៤ | ការបញ្ចាំងភាពយន្ត វីដេអូ ផ្សាយពាណិជ្ជកម្ម | | ១៥ ០០០ | ៧ ថ្ងៃ | ១ ថ្ងៃ | ១ ច្បាប់ |
| ៥ | ការបញ្ចាំងភាពយន្ត វីដេអូ កំដរពិធីបុណ្យផ្សេងៗ | | ១៥ ០០០ | ៧ ថ្ងៃ | ១ ថ្ងៃ | ១ ច្បាប់ |
| ៦ | ការបញ្ចាំងភាពយន្ត វីដេអូ កំដរភ្ញៀវ | | ២៥ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៤.៣. អាជីវកម្មលក់ ជួលស្នាដៃភាពយន្ត វីដេអូ | | | | | | |
| ៧ | ហាងលក់ ជួល ស៊ីឌី វីស៊ីឌី ឌីវីឌី | | ៤០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៤.៤. ស្លាកសញ្ញាអាជីវកម្ម | | | | | | |
| ៨ | ផ្ទាំងយីហោគ្រប់ប្រភេទ ទំហំក្រោម ២ម៉ែត្រការ៉េ | | ៤០ ០០០ | ៧ ថ្ងៃ | ២ ឆ្នាំ | ១ ច្បាប់ |
| ៩ | ផ្ទាំងយីហោគ្រប់ប្រភេទ ទំហំចាប់ពី ២ម៉ែត្រការ៉េ ដល់ ៤ម៉ែត្រការ៉េ | | ៥០ ០០០ | ៧ ថ្ងៃ | ២ ឆ្នាំ | ១ ច្បាប់ |
| ១០ | ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្ម (Poster) | | ២៥ ០០០ | ៧ ថ្ងៃ | ៣ ខែ | ១ ច្បាប់ |
| ១១ | ផ្ទាំងរូបភាព និមិត្តសញ្ញាផ្សេងៗ ទំហំក្រោម ២ម៉ែត្រការ៉េ | | ៤០ ០០០ | ៧ ថ្ងៃ | ២ ឆ្នាំ | ១ ច្បាប់ |
| ១២ | ផ្ទាំងរូបភាព និមិត្តសញ្ញាផ្សេងៗ ទំហំចាប់ពី ២ម៉ែត្រការ៉េ ដល់ ៤ម៉ែត្រការ៉េ | | ៥០ ០០០ | ៧ ថ្ងៃ | ២ ឆ្នាំ | ១ ច្បាប់ |
| ១៣ | បដាផ្សាយពាណិជ្ជកម្ម | | ១៥ ០០០ | ៧ ថ្ងៃ | ៣ ខែ | ១ ច្បាប់ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| **៤.៥. អាជីវកម្មគ្រឿងបំពងសម្លេង** | | | | | | |
| ១៤ | ជួលធុងបាស់ និងឧត្បោសនសព្ទ | | ៥ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| **៤.៦. អាជីវកម្មលក់សៀវភៅ** | | | | | | |
| ១៥ | បណ្ណាគារ | | ១០០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| **៤.៧. អាជីវកម្មសិល្បៈសូនរូប** | | | | | | |
| ១៦ | ទីតាំងផលិត និងលក់ចម្លាក់ ពុម្ពស៊ីម៉ងត៍ | | ១០០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១៧ | ជាងគំនូរ | | ៤០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| **៤.៨. អាជីវកម្មថតរូប** | | | | | | |
| ១៨ | អគារថតរូប (មានស្ទីឌីយោ) | | ១០០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១៩ | ផ្ទះថតរូប | | ២៥ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| **៤.៩. អាជីវកម្មកាត់សក់ អ៊ុតសក់ លម្អក្រចក និងសម្អាងការ (ហាង)** | | | | | | |
| ២០ | កាត់សក់បុរស (ចាប់ពី ២កៅអី ទៅ ៤កៅអី) | | ២០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២១ | កាត់សក់បុរស (ចាប់ពី ៥កៅអី ឡើងទៅ) | | ៤០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២២ | អ៊ុតសក់ កាត់សក់ លម្អក្រចក (ចាប់ពី ២កៅអី ទៅ ៤កៅអី) | | ៤០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២៣ | អ៊ុតសក់ កាត់សក់ លម្អក្រចក (ចាប់ពី ៥កៅអី ឡើងទៅ) | | ៦០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២៤ | សម្អាងការ (តម្លៃក្រោម ៥០០ដុល្លារអាម៉េរិក) | | ១០០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២៥ | សម្អាងការ (តម្លៃចាប់ពី ៥០០ដុល្លារអាម៉េរិក ដល់ក្រោម ១ ០០០ដុល្លារអាម៉េរិក) | | ២០០ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| **៥. វិស័យអប់រំ យុវជន និងកីឡា** | | | | | | |
| ១ | សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីជាតិ) | | ២០០ ០០០ | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ២ | ការធ្វើសុពលភាពឡើងវិញ | | ១០០ ០០០ | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៣ | សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន (កម្មវិធីអន្តរជាតិ) | | ៤០០ ០០០ | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៤ | ការធ្វើសុពលភាពឡើងវិញ | | ២០០ ០០០ | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៥ | ថ្នាក់បណ្ដុះបណ្ដាលជំនាញ និងភាសាបរទេសវគ្គខ្លីៗ តិចជាង ១ឆ្នាំ | | ២០០ ០០០ | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៦ | ការធ្វើសុពលភាពឡើងវិញ | | ១០០ ០០០ | ២០ ថ្ងៃ | ៥ ឆ្នាំ | ១ ច្បាប់ |
| ៧ | បង្កើតក្លឹបហាត់ប្រាណ | | ២០០ ០០០ | ២០ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៨ | ការធ្វើសុពលភាពឡើងវិញ | | ១០០ ០០០ | ២០ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៩ | អាជីវកម្មលក់សម្ភារកីឡា | | ២០០ ០០០ | ២០ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១០ | ការធ្វើសុពលភាពឡើងវិញ | | ១០០ ០០០ | ២០ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| **៦. វិស័យទេសចរណ៍** | | | | | | |
| ១ | ផ្ទះសំណាក់ ចាប់ពី ០៨បន្ទប់ ចុះក្រោម (គិតក្នុង ០១បន្ទប់) | | ១៥ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ២ | ផ្ទះជួលបន្ទប់ស្នាក់នៅ (គិតក្នុង ០១បន្ទប់) | | ៥ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៣ | ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ ចាប់ពី ៥០នាក់ ចុះក្រោម | | ៣០០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៤ | ភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក | | ១០០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៥ | តូបលក់អាហារ | | ១០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេល អតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | |
| ៦ | ហាងលក់គុយទាវ កាហ្វេ | | ៥០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៧ | ម៉ាស្សា ចាប់ពី ០៥គ្រែ ឬចាប់ពី ០៥កៅអី ចុះក្រោម | | ២៦០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៨ | ខារ៉ាអូខេ ចាប់ពី ០៥បន្ទប់ ចុះក្រោម | | ៤០០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ៩ | ស្នូកឃ័រ ចាប់ពី ០៥តុ ចុះក្រោម | | ១៥០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១០ | រថយន្តដឹកទេសចរណ៍ ចំណុះចាប់ពី ០៥កៅអី ចុះក្រោម | | ១០០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១១ | ម៉ូតូឌុបទេសចរណ៍ | | ១០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១២ | ម៉ូតូជួលទេសចរណ៍ | | ១០ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១៣ | រ៉ឺម៉កម៉ូតូដឹកទេសចរណ៍ | | ១៥ ០០០ | ២៨ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | | រយៈពេល អតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | | |
| | | | ក្រៅក្រុង | ក្នុងក្រុង | | | |
| **៧. វិស័យសំណង់** | | | | | | | |
| **៧.១. លិខិតអនុញ្ញាតសាងសង់** | | | | | | | |
| **ភូមិគ្រឹះ** | | | | | | | |
| ១ | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | | ៤២០ ០០០ | ៦០០ ០០០ | ២៥ ថ្ងៃ | | |
| ២ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | | ៥៦០ ០០០ | ៨០០ ០០០ | ២៥ ថ្ងៃ | | |
| ៣ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | | ៧០០ ០០០ | ១ ០០០ ០០០ | ២៥ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | | |
| | | | ក្រៅក្រុង | ក្នុងក្រុង | | | |
| ៤ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | | ៩៨០ ០០០ | ១ ៤០០ ០០០ | ២៥ ថ្ងៃ | | |
| ៥ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | | ១ ២៦០ ០០០ | ១ ៨០០ ០០០ | ២៥ ថ្ងៃ | | |
| **ផ្ទះល្វែង** | | | | | | | |
| ៦ | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | | ២៨០ ០០០ | ៤០០ ០០០ | ២៥ ថ្ងៃ | | |
| ៧ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | | ៣៥០ ០០០ | ៥០០ ០០០ | ២៥ ថ្ងៃ | | |
| ៨ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | | ៤២០ ០០០ | ៦០០ ០០០ | ២៥ ថ្ងៃ | | |
| ៩ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | | ៥៦០ ០០០ | ៨០០ ០០០ | ២៥ ថ្ងៃ | | |
| ១០ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | | ៨៤០ ០០០ | ១ ២០០ ០០០ | ២៥ ថ្ងៃ | | |
| **ថ្មក្រោមឈើលើ** | | | | | | | |
| ១១ | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | | ៩៨ ០០០ | ១៤០ ០០០ | ២៥ ថ្ងៃ | | |
| ១២ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | | ១១២ ០០០ | ១៦០ ០០០ | ២៥ ថ្ងៃ | | |
| ១៣ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | | ១២៦ ០០០ | ១៨០ ០០០ | ២៥ ថ្ងៃ | | |
| ១៤ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | | ១៤០ ០០០ | ២០០ ០០០ | ២៥ ថ្ងៃ | | |
| ១៥ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | | ១៥៤ ០០០ | ២២០ ០០០ | ២៥ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | | |
| | | | ក្រៅក្រុង | ក្នុងក្រុង | | | |
| ៧.២. លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល | | | | | | | |
| ភូមិគ្រឹះ | | | | | | | |
| ១៦ | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ១៧ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ១៨ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ១៩ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ២០ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ផ្ទះល្វែង | | | | | | | |
| ២១ | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ២២ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ២៣ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ២៤ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ២៥ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ថ្មក្រោមឈើលើ | | | | | | | |
| ២៦ | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ២៧ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ២៨ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | | រយៈពេលអតិបរមា (ថ្ងៃធ្វើការ) | សុពលភាព | ចំនួន |
|---|---|---|---|---|---|---|---|
| | | តម្លៃអតិបរមា | តម្លៃជាក់លាក់ | | | | |
| | | | ក្រៅក្រុង | ក្នុងក្រុង | | | |
| ២៩ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| ៣០ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ២០ ថ្ងៃ | | |
| **៧.៣. លិខិតអនុញ្ញាតបើកការដ្ឋាន** | | | | | | | |
| **ភូមិគ្រឹះ** | | | | | | | |
| ៣១ | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ០៧ ថ្ងៃ | | |
| ៣២ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ០៧ ថ្ងៃ | | |
| ៣៣ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ២០០ម៉ែត្រការ៉េ ដល់ ៣០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ០៧ ថ្ងៃ | | |
| ៣៤ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៣០០ម៉ែត្រការ៉េ ដល់ ៤០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ០៧ ថ្ងៃ | | |
| ៣៥ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ៤០០ម៉ែត្រការ៉េ ដល់ ៥០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ០៧ ថ្ងៃ | | |
| **ផ្ទះល្វែង** | | | | | | | |
| ៣៦ | ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ១០០ម៉ែត្រការ៉េ ចុះក្រោម | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ០៧ ថ្ងៃ | | |
| ៣៧ | ផ្ទៃក្រឡាកម្រាលសំណង់ លើសពី ១០០ម៉ែត្រការ៉េ ដល់ ២០០ម៉ែត្រការ៉េ | | ១០% នៃតម្លៃលិខិតអនុញ្ញាត | | ០៧ ថ្ងៃ | | |
